# វគ្គបណ្តុះបណ្តាល
# ស្តីពី
# ការកំណត់អត្តសញ្ញាណជនរងគ្រោះ
# ដោយអំពើជួញដូរមនុស្សដើម្បីដើម្បីផ្តល់សេវាសមស្រប

*រៀបរៀងដោយ:* **លោកជំទាវ ជូ ប៊ុនអេង** *រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជា អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ*

*មេរៀនទី ៦ ៖* បែបបទនីតិវិធីនៃការបញ្ជូន

*ធ្វើបទបង្ហាញដោយ៖* ***ឧត្តមសេនីត្រី អ៊ិន មាន***

*ប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ*

# ផ្នែកទី៣

## បែបបទនីតិវិធីនៃការបញ្ជូន

ទំព័រទី ២៣

# រំលឹកមេរៀន

- សិទ្ធិជនរងគ្រោះ
- ការផ្តល់សេវាជូនជនរងគ្រោះ
- អ្នកមានសមត្ថកិច្ចកំណត់ អត្តសញ្ញាណ
- វិនិច្ឆ័យសម្រាប់កំណត់សម្គាល់ជនរងគ្រោះ
- ទម្រង់បែបបទខ្លី សម្រាប់ការសម្ភាសន៍រហ័ស
- ទម្រង់បែបបទខ្លវែង សម្រាប់ការសម្ភាសន៍លម្អិត

# រំលឹកមេរៀន

## អ្នកមានភារកិច្ចកំណត់អត្តសញ្ញាណបឋម

**សមត្ថកិច្ចអាជ្ញាធរមូលដ្ឋាន**

- រាជធានី
- ខេត្ត
- ខណ្ឌ
- ស្រុក
- ក្រុង
- សង្កាត់
- ឃុំ

នគរបាលយុត្តិធម៌

មន្ត្រីសង្គមកិច្ច

មន្ត្រីទទួលបន្ទុកកិច្ចការនារី និងកុមារ

មន្ត្រីក្នុងរចនាសម្ព័ន្ធថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ

មន្ត្រីបេសកកម្មការទូត

ទីភ្នាក់ងារផ្តល់ការគាំទ្រជនរងគ្រោះ

អង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធ និងទទួលបានសិទ្ធិ

# គំនូសបំព្រួញនៃប្រព័ន្ធបញ្ជូន



# វិធានការសំខាន់ៗក្រោយពេលកំណត់អត្តសញ្ញាណជនរងគ្រោះ ដើម្បីបញ្ជូនទៅរកសេវា

# ទំនាក់ទំនង



រាល់ការបញ្ជូនជនរងគ្រោះ ឬជនសង្ស័យថារងគ្រោះ ពីកន្លែងមួយទៅកន្លែងមួយទៀត មន្ត្រី ឬអ្នកមានសមត្ថកិច្ចដែលជាតំណាងស្ថាប័ន និងជាអ្នកមានភារកិច្ចការពារជនរងគ្រោះ ត្រូវទំនាក់ទំនងជាមួយស្ថាប័ន ឬអង្គភាព ឬកន្លែងទទួលបន្តជាមុន ដោយធានាថាទីនោះ ជាកន្លែងដែលមានសុវត្ថិភាព មានការទទួលខុសត្រូវសម្រាប់ជនរងគ្រោះ ឬជនសង្ស័យថារងគ្រោះ ដែលនឹងបញ្ជូនទៅ (អាចជាស្ថាប័នរដ្ឋ អាជ្ញាធរមូលដ្ឋាន សមត្ថកិច្ចនគរបាលយុត្តិធម៌ ឬអង្គការដែលបានចុះបញ្ជីតាមផ្លូវច្បាប់) មានអ្នកទទួលខុសត្រូវ លើជនដែលសង្ស័យថារងគ្រោះ។

# ទំនាក់ទំនង

**បញ្ជូន**

- ស្ថាប័នរដ្ឋ
- អាជ្ញាធរមូលដ្ឋាន
- នគរបាលយុត្តិធម៌
- អង្គការ

រៀបចំផែនការ

សុវត្ថិភាព?

មានកន្លែងសមរម្យ?

→

←

សេចក្តីណែនាំផ្សេងៗ

**ទទួល**

- ស្ថាប័នរដ្ឋ
- អាជ្ញាធរមូលដ្ឋាន
- នគរបាលយុត្តិធម៌
- អង្គការ

រៀបចំផែនការ

# សុវត្ថិភាពជនរងគ្រោះ



ការបញ្ជូន ត្រូវធ្វើឡើងដោយមានការទទួលខុសត្រូវលើសុវត្ថិភាពជនរងគ្រោះ ឬជនសង្ស័យថារងគ្រោះ ដែលត្រូវបញ្ជូនទៅ ឬការទទួលយកទៅ ដោយមិនធ្វើឲ្យជនរងគ្រោះរឹតតែមានការបារម្ភ ឬភ័យខ្លាច ឬគេចវេស ឬត្រូវបានជនដទៃដែលមិនមានសមត្ថកិច្ចទាមទារ ឬនាំចេញទៅដោយគ្មានការទទួលខុសត្រូវ។

# ឯកសារ



- ការបញ្ជូន ចាំបាច់ត្រូវភ្ជាប់ជាមួយឯកសារ ពាក់ព័ន្ធនឹងជនរងគ្រោះ ឬលទ្ធផលនៃការកំណត់អត្តសញ្ញាណ (ច្បាប់ចម្លង) ដោយមានហត្ថលេខា សាមីខ្លួន អ្នកកំណត់សទ្ទសញ្ញាណ និងប្រធានអង្គភាព ឬតំណាង និងមានកាលបរិច្ឆេទ ត្រឹមត្រូវ។
- ការបញ្ជូន ត្រូវមានឯកសារប្រគល់ និងទទួល ដោយមានហត្ថលេខា ឬស្នាមមេដៃអ្នកប្រគល់ និងអ្នកទទួល ដោយថតចម្លងជាពីរច្បាប់ សម្រាប់ស្ថាប័ន ឬអង្គភាពខាងអ្នកប្រគល់មួយច្បាប់ និងខាងអ្នកទទួល មួយច្បាប់ ដើម្បីទុកជាឯកសារ។

ទម្រង់បញ្ជូនទៅរកសេវា តាមសារាចរណែនាំ លេខ ០០៩ ស.អ.យ. ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៧របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## ទម្រង់បញ្ជូន

ជូនចំពោះ : លោក/លោកស្រី.................តួនាទី.................ស្ថាប័ន/អង្គការ :.................

ពី : លោក/លោកស្រី.................តួនាទី.................ស្ថាប័ន/អង្គការ.................

**១. សេវាដែលស្នើសុំឬគោលបំណងនៃការបញ្ជូន**

.................................................................................................

.................................................................................................

**២. ព័ត៌មានអំពីជនរងគ្រោះ**

ឈ្មោះ :.................ភេទ :.................អាយុ.................អាសយដ្ឋានបច្ចុប្បន្ន :.................

ស្ថានភាពបញ្ហាដែលជនរងគ្រោះកំពុងប្រឈមនាពេលបច្ចុប្បន្ន :.................................

.................................................................................................

.................................................................................................

**៣. ការសង្កេត និងចំណាប់អារម្មណ៍របស់បុគ្គលិកសង្គមកិច្ច**

.................................................................................................

.................................................................................................

**៤. ការឆ្លើយតប និងការសម្រេចចិត្តរបស់ស្ថាប័នទទួល**

.................................................................................................

.................................................................................................

.................................................................................................

សូមអរគុណលោក-លោកស្រី សម្រាប់ការយកចិត្តទុកដាក់ និងការជួយ។

ឈ្មោះ និងតួនាទីរបស់តំណាងស្ថាប័នទទួល:

.................................................................

ហត្ថលេខា និងត្រា: .................................

កាលបរិច្ឆេទ : ........./........./.........

ឈ្មោះ និងតួនាទីរបស់បុគ្គលិកសង្គមកិច្ចដែលធ្វើការបញ្ជូន :

.................................................................

ហត្ថលេខា និងត្រា: .................................

កាលបរិច្ឆេទធ្វើការបញ្ជូន : ........./........./.........

# ឧទាហរណ៍ ទម្រង់បញ្ជូន

ជូនចំពោះ ៖ លោក/លោកស្រី.......................តួនាទី...................... ស្ថាប័ន/អង្គការ ៖ ...............................

ពី ៖ លោក/លោកស្រី....................................តួនាទី ......................ស្ថាប័ន/អង្គការ................................

# ឧទាហរណ៍ ទម្រង់បញ្ជូន

១. សេវាដែលស្នើសុំឬគោលបំណងនៃការបញ្ជូន

........................................................................................................................................

........................................................................................................................................

# ឧទាហរណ៍ ទម្រង់បញ្ជូន

**២. ព័ត៌មានអំពីជនរងគ្រោះ**

ឈ្មោះ :..............................................................ភេទ :.....................អាយុ ..............................អាសយដ្ឋានបច្ចុប្បន្ន :...........................................

ស្ថានភាព/បញ្ហាដែលជនរងគ្រោះកំពុងប្រឈមនាពេលបច្ចុប្បន្ន :............................................ .........................................................

....................................................................................................................................................................................................................................

.................................................................................................................................................................................................... ..........................................................

# ឧទាហរណ៍ ទម្រង់បញ្ជូន

ឈ្មោះ និងតួនាទីរបស់តំណាងស្ថាប័នទទួល:
.......................................................................................

ហត្ថលេខា និងត្រា: .............................................

កាលបរិច្ឆេទ : ............/............./.............

ឈ្មោះ និងតួនាទីរបស់បុគ្គលិកសង្គមកិច្ចដែលធ្វើការបញ្ជូន :
.......................................................................................................

ហត្ថលេខា និងត្រា: ...........................................................

កាលបរិច្ឆេទធ្វើការបញ្ជូន : ............/............./.............

# របាយការណ៍



ស្ថាប័ន ឬអង្គភាពអ្នកប្រគល់ និងអ្នកទទួល ត្រូវធ្វើរបាយការណ៍ជាប្រចាំ ទៅការិយាល័យ ឬមន្ទីរសង្គមកិច្ច ឬប្រធានលេខាធិការដ្ឋាន ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី ខេត្ត ដើម្បីធ្វើការបូកសរុបទិន្នន័យ និងតាមដានស្ថានភាពជនរងគ្រោះ។

# របាយការណ៍

រាជរដ្ឋាភិបាល

↑ តួលេខនិងនិន្នាការ ស្នើអនុសាសន៍

គជបជ

↑ តួលេខនិងនិន្នាការ

គរបជ/គខបជ

↑ តាមដានស្ថានភាពជនរងគ្រោះ

ការិយាល័យ ឬមន្ទីរសង្គមកិច្ច ↔ តាមដានស្ថានភាពជនរងគ្រោះ ↔ ស្ថាប័ន ឬអង្គភាពអ្នកប្រគល់ និងអ្នកទទួល

# វិធានការបញ្ជូន
# ករណីជនរងគ្រោះជាជនជាតិកម្ពុជា

- ជនរងគ្រោះកម្ពុជាដែលនៅក្នុងប្រទេស៖ ត្រូវបញ្ជូនជនរងគ្រោះទៅរកសេវាផ្សេងៗ ឬធ្វើសមាហរណកម្ម ទៅកាន់សហគមន៍ដើម ឬកន្លែងរស់នៅថ្មី ដែលនឹងត្រូវសម្របសម្រួលនិងផ្តល់ការគាំទ្រដោយ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាជ្ញាធរមូលដ្ឋាន ទីភ្នាក់ងារផ្តល់សេវាគាំទ្រជនរងគ្រោះ និងអង្គការជាតិ-អន្តរជាតិផ្សេងៗ។ ( ឧបសម្ព័ន្ធទី៥ ទំព័រ៥៧ )
- ជនរងគ្រោះកម្ពុជានៅបរទេស៖ ត្រូវគាំទ្រដោយតំណាងបេសកកម្មការទូតរបស់ប្រទេសកម្ពុជាប្រចាំនៅប្រទេស ឬតំបន់នោះ និងទីភ្នាក់ងារផ្តល់សេវាគាំទ្រជនរងគ្រោះ។ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចចាត់ចែងសម្របសម្រួលជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងមហាផ្ទៃ (អគ្គស្នងការដ្ឋាននគរបាលជាតិ ) ដើម្បីរៀបចំការធ្វើមាតុភូមិនិវត្តន៍ និងធ្វើសមាហរណកម្ម ស្របតាមបែបបទជាធរមាន។

# វិធានការបញ្ជូន ករណីជនរងគ្រោះជាជនបរទេស

- បើជនរងគ្រោះជាជនបរទេស នៅប្រទេសដែលមានកិច្ចព្រមព្រៀងជាមួយប្រទេសកម្ពុជា ការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះត្រូវអនុវត្តស្របតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនោះ។
- បើជនរងគ្រោះជាជនបរទេស នៃប្រទេសដែលមិនមានកិច្ចព្រមព្រៀង ជាមួយប្រទេសកម្ពុជា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវសម្របសម្រួលជាមួយក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងទីភ្នាក់ងារផ្តល់សេវាគាំទ្រជនរងគ្រោះ ដើម្បីចាត់ចែង និងរៀបចំការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះស្របតាមនីតិវិធីជាធរមាន។

# គំនូសបំព្រួញនៃប្រព័ន្ធបញ្ជូន



# សូមអរគុណ